# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៨.....អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា១ .–**

ត្រូវបានបង្កើតក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ដែលមានគោលបំណងលើកកម្ពស់វិស័យកីឡារបស់កងកម្លាំងនគរបាលជាតិ និងរួមគ្នាអភិវឌ្ឍសមត្ថភាព បច្ចេកទេសឱ្យមានការរីកចម្រើន ដើម្បីធ្វើសមាហរណកម្មចូលជាសមាជិកសហភាពកីឡានគរបាលអន្តរជាតិ International Police Sport Union សរសេរជាអក្សរកាត់ "IPUS" ។

**មាត្រា២ .–**

ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ មានតួនាទី ភារកិច្ច ដូចខាងក្រោម ៖

- គ្រប់គ្រង ដឹកនាំអង្គភាពកីឡានគរបាលជាតិ ស្របតាមលក្ខន្តិកៈរបស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ សម្រាប់អាណត្តិទី២ (២០១៨-២០២២) និងអាណត្តិបន្តបន្ទាប់ក្រោយៗទៀត

- ដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីឱ្យអង្គភាពកីឡានគរបាលជាតិអនុវត្តតាមគោលការណ៍កំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល

- បែងចែកភារកិច្ច ដឹកនាំ និងទទួលខុសត្រូវ តាមវិស័យជំនាញកីឡានីមួយៗ អនុលោមតាមស្មារតីនៃអង្គប្រជុំវិសាមញ្ញ ដើម្បីអនុវត្តតាមសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ នឹងរួមចំណែកឱ្យបានខ្លាំងក្នុងការពង្រឹងកិច្ចអភិវឌ្ឍធនធានកីឡាក្នុងកងកម្លាំងនគរបាលជាតិ សំដៅលើកស្ទួយកិត្តិយសកិត្យានុភាពក្នុងវិស័យកីឡាទាំងនៅថ្នាក់ជាតិ និងលើឆាកអន្តរជាតិ

- សហការជាមួយវិស័យកីឡាផ្សេងៗនៅតាមក្រសួង ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា

- ពិនិត្យសមត្ថភាពជំនាញ កាយសម្បទារបស់កីឡាករ-កីឡាការិនី និងលើកសំណើសុំនាយករដ្ឋមន្ត្រីបញ្ចូលក្នុងក្របខ័ណ្ឌកងកម្លាំងនគរបាលជាតិជំនួសឱ្យមន្ត្រី គ្រូបង្វឹកកីឡាករ-កីឡាការិនីចាស់ៗដែលត្រូវដាក់ឱ្យចូលនិវត្តន៍ជារៀងរាល់ឆ្នាំ មិនឱ្យលើសពី ៥% (ប្រាំភាគរយ)នៃកងកម្លាំងសរុប ក្នុងអង្គភាពកីឡានគរបាលជាតិ ដោយគិតចាប់តាំងពីឆ្នាំ ២០១៩ តទៅ ។

## ជំពូកទី២

## សមាសភាពគណៈកម្មាធិការប្រតិបត្តិរបស់ ក.ក.ម.ផ និងរចនាសម្ព័ន្ធ

**មាត្រា៣ .—**

**ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ មានសមាសភាព ដូចខាងក្រោម ៖**

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២-អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធានទី១ |
| ៣-អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ | អនុប្រធានទី២ |
| ៤-នាយកខុទ្ទកាល័យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥-អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | អនុប្រធាន |
| ៦-អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | អនុប្រធាន |
| ៧-អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៨-ប្រធានក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៩-ប្រធានបណ្ឌិត្យសភានគរបាលជាតិកម្ពុជា | អនុប្រធាន |
| ១០-ប្រធាននាយកដ្ឋានបុគ្គលិកនគរបាលជាតិ | អនុប្រធាន |
| ១១-ប្រធានអង្គភាពកីឡានគរបាលជាតិក្រសួងមហាផ្ទៃ | អគ្គលេខាធិការ |
| ១២-តំណាងជាន់ខ្ពស់កងកម្លាំងនគរបាលជាតិ ០២រូប | អគ្គលេខាធិការរង |
| ១៣-ប្រធាននាយកដ្ឋាន និងអង្គភាពនានាចំណុះក្រសួង | សមាជិក |
| ១៤-អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត | សមាជិក |
| ១៥-ស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត | សមាជិក ។ |

**មាត្រា៤ .—**

ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ មានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

អង្គភាពកីឡានគរបាលជាតិ ធ្វើជាសេនាធិការ ឱ្យក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ដឹកនាំដោយប្រធាន មួយរូប មានឋានៈនិងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធាន មួយចំនួន ជាជំនួយការ មានឋានៈនិងបុព្វសិទ្ធិស្មើអនុប្រធាននាយកដ្ឋាននានា ចំណុះក្រសួងមហាផ្ទៃ ដែលមានទីតាំងនៅអាគារស្ថិតនៅប៉ែកខាងត្បូងអាងហែលទឹក ក្នុងពហុកីឡាដ្ឋានជាតិ សង្កាត់វាលវង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

**មាត្រា៥ .–**

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អង្គភាពកីឡានគរបាលជាតិក្រសួងមហាផ្ទៃ កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**ជំពូកទី៣**

**ប្រភពធនធាន និងថវិកា**

**មាត្រា៦ .–**

ប្រភពធនធាន និងថវិកាសម្រាប់ដំណើរការ ត្រូវប្រើប្រាស់កញ្ចប់ថវិកាបានមកពីសប្បុរសជនជាតិ និងអន្តរជាតិ ជា"មូលនិធិកីឡាក្រសួងមហាផ្ទៃ" ។ **ក.ក.ម.ផ** មានសិទ្ធិទទួល និងប្រើប្រាស់ថវិកានេះ សម្រាប់ចាត់ចែងដំណើរការការងាររបស់ខ្លួន ។

**មាត្រា៧ .–**

អង្គភាពកីឡានគរបាលជាតិក្រសួងមហាផ្ទៃ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែកនៅក្នុងឧបសម្ព័ន្ធនៃកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៨ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៩ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ប្រធានស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងស្នងការ នៃស្នងការនគរបាលរាជធានី ខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃសុក្រ ៥ រោច ខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស ២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៨*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
**សូមហត្ថលេខា**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ